## ទីក្រុងឡុងប៊ិច
## ការវិភាគមិនលំអៀងរបស់មេធាវីក្រុង នៃវិធានការ E

## វិសោធនកម្មធម្មនុញ្ញ ដើម្បីបន្ថែមនាយកត្រួតពិនិត្យប៉ូលីស និងគណៈកម្មាការត្រួតពិនិត្យប៉ូលីស ដែលនឹងជំនួសអោយ គណៈកម្មាការពលរដ្ឋធ្វើបណ្ដឹងលើប៉ូលីសរបស់ទីក្រុង

នៅថ្ងៃទី 9 ខែសីហា ឆ្នាំ 2022 ក្រុមប្រឹក្សាក្រុងឡុងប៊ិចបានដាក់វិធានការ E នៅលើសន្លឹកឆ្នោត។ វិធានការនេះ នឹងធ្វើវិសោធនកម្មធម្មនុញ្ញទីក្រុងឡុងប៊ិច ដើម្បីបន្ថែមប្រធាននាយកដ្ឋានត្រួតពិនិត្យប៉ូលីស និងគណៈកម្មការត្រួតពិនិត្យប៉ូលីស ដែលនឹងជំនួសអោយគណៈកម្មការពលរដ្ឋធ្វើបណ្ដឹងលើប៉ូលីស។

មាត្រា XIA នៃធម្មនុញ្ញទីក្រុងបានបង្កើតគណៈកម្មការពលរដ្ឋធ្វើបណ្ដឹងលើប៉ូលីស ("CPCC") ដែលមានសមាសភាពនៃស្នងការចំនួន 11 ដែលត្រូវបានតែងតាំងដោយអភិបាលក្រុង និងបញ្ជាក់ដោយក្រុមប្រឹក្សាក្រុង, ដោយផ្ដល់នូវអំណាច និងភារកិច្ចក្នុងការគ្រប់គ្រង និងស៊ើបអង្កេត, តាមរយៈអ្នកស៊ើបអង្កេតឯករាជ្យ ដែលត្រូវបានតែងតាំងដោយអ្នកគ្រប់គ្រងទីក្រុង, ការចោទប្រកាន់អំពីការប្រព្រឹត្តខុសច្បាប់របស់ប៉ូលិស។ CPCC មានសិទ្ធិអំណាចក្នុងការធ្វើសវនាការ, ដីកាកោះហៅ និងទាមទារឱ្យមានការចូលរួមពីសាក្សី និងការផលិតឯកសារពាក់ព័ន្ធទៅនឹងការស៊ើបអង្កេត; និងផ្តល់អនុសាសន៍ទាក់ទងនឹងការប្រព្រឹត្តខុស ទៅអោយអ្នកគ្រប់គ្រងទីក្រុង ដែលអ្នកគ្រប់គ្រងទីក្រុងមានសិទ្ធិអំណាចចុងក្រោយលើការដាក់វិន័យ។

វិធានការនេះនឹងធ្វើវិសោធនកម្ម និងកំណត់ឡើងវិញនូវមាត្រា XIA នៃធម្មនុញ្ញទីក្រុង ដើម្បីជំនួស CPCC ជាមួយនឹងនាយកត្រួតពិនិត្យប៉ូលីស ("នាយក") និងគណៈកម្មការត្រួតពិនិត្យប៉ូលីស ("គណៈកម្មការ")។

នាយកនឹងត្រូវបានតែងតាំងដោយក្រុមប្រឹក្សាក្រុង និងមានសិទ្ធិធ្វើសវនកម្មការស៊ើបអង្កេតទាំងអស់ ដែលបានបញ្ចប់ដោយនាយកដ្ឋានកិច្ចការផ្ទៃក្នុងរបស់នាយកដ្ឋានប៉ូលីស ("IA") សម្រាប់ការឆ្លើយតបទាន់ពេលវេលា, ហ្មត់ចត់ និងគុណភាព; ពិនិត្យមើលការទទួលយកពាក្យបណ្ដឹងរបស់ IA ដើម្បីធានាថាការចោទប្រកាន់សមស្រប ត្រូវបានដាក់បញ្ចូលនៅក្នុងការស៊ើបអង្កេតរបស់ IA; រៀបចំរបាយការណ៍ប្រចាំឆ្នាំដោយផ្ដោតលើនិន្នាការស្ថិតិ និងរបាយការណ៍ពិសេស ហើយផ្តល់របាយការណ៍បែបនេះដល់គណៈកម្មការ និងក្រុមប្រឹក្សាក្រុង; និងពិនិត្យមើលលើប្រតិបត្តិការ, គោលនយោបាយ, នីតិវិធី និងវគ្គបណ្តុះបណ្តាលរបស់នាយកដ្ឋាននគរបាល និងផ្តល់អនុសាសន៍លើការពិនិត្យនេះជូនគណៈកម្មការ និងក្រុមប្រឹក្សាក្រុង។ នាយកនឹងមានសិទ្ធិអំណាចនៅកន្លែងកើតហេតុធ្ងន់ធ្ងរ ដើម្បីសង្កេតមើលការចាត់ចែងរបស់នាយកដ្ឋានប៉ូលិស ក្នុងការស៊ើបអង្កេត។ តាមការស្នើសុំរបស់អ្នកគ្រប់គ្រងទីក្រុង នាយកនឹងត្រូវបានអនុញ្ញាតក្នុងការធ្វើការស៊ើបអង្កេតដោយឯករាជ្យ លើបណ្ដឹងប្រឆាំងទៅនឹងស្នងការនគរបាល និងបុគ្គលិកបញ្ជាការ រួមជាមួយនឹងការប្រើប្រាស់កម្លាំងហួសហេតុដែលពាក់ព័ន្ធនឹងការស្លាប់ ឬរបួសរាងកាយធ្ងន់ធ្ងរ, ការបាញ់ប្រហារដែលពាក់ព័ន្ធនឹងមន្ត្រី, ការស្លាប់នៅក្នុងមន្ទីរឃុំឃាំង និងឧប្បត្តិហេតុធ្ងន់ធ្ងរ ហើយនឹងអាចចូលប្រើឬពិនិត្យមើលកំណត់ត្រាពាក់ព័ន្ធទាំងអស់របស់នាយកដ្ឋានប៉ូលីស និងមានអំណាចក្នុងការសាកសួរសាក្សី រួមទាំងបុគ្គលិកនាយកដ្ឋានប៉ូលីស ផងដែរ។

គណៈកម្មការនេះ នឹងមានសមាសភាពស្នងការចំនួនប្រាំពីររូប ដែលតែងតាំងដោយអភិបាលក្រុង និងមានការបញ្ជាក់ដោយក្រុមប្រឹក្សាក្រុង។ គណៈកម្មាការនេះនឹងផ្តល់ឱ្យនាយកនូវអាទិភាពសវនកម្មដោយផ្អែកលើមតិកែលម្អ និងការចូលរួមរបស់សហគមន៍; ទទួលសេចក្តីសង្ខេបអំពីឧប្បត្តិហេតុដែលមានទម្រង់ខ្ពស់; ពិនិត្យ និងអនុម័តអនុសាសន៍ដែលធ្វើឡើងដោយនាយក; និងផ្តល់មតិកែលម្អលើរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ពិសេសនានារបស់នាយក។

មានផលប៉ះពាល់សារពើពន្ធដែលអាចកើតមាន ទាក់ទងនឹងវិធានការនេះ។ ការចំណាយលើរចនាសម្ព័ន្ធដែលរំពឹងទុកចំពោះមូលនិធិ

ទូទៅ ត្រូវបានគេប៉ាន់ប្រមាណថាមានចំនួនប្រហែល $900,000 ។

ការបោះឆ្នោត "បាទ/ចាស" គឺគាំទ្រដល់ការបង្កើតគណៈកម្មការត្រួតពិនិត្យប៉ូលីស និងបន្ថែមនាយកត្រួតពិនិត្យប៉ូលីស ដើម្បីជំនួសអោយគណៈកម្មការពលរដ្ឋធ្វើបណ្តឹងលើប៉ូលីស ដែលមានស្រាប់។

ការបោះឆ្នោត "ទេ" គឺប្រឆាំងទៅនឹងការបង្កើតគណៈកម្មការត្រួតពិនិត្យប៉ូលីស និងការបន្ថែមនាយកត្រួតពិនិត្យប៉ូលីស ហើយនឹងរក្សាទុកនូវគណៈកម្មការពលរដ្ឋធ្វើបណ្តឹងលើប៉ូលីស ដែលមានស្រាប់។

តម្រូវអោយមានសំឡេងភាគច្រើន បោះឆ្នោត "បាទ/ចាស" ដើម្បីឱ្យវិធានការនេះអនុម័ត/ឈ្នះ។

**សេចក្តីថ្លែងការណ៍ខាងលើនេះ គឺជាការវិភាគមិនលំអៀងចំពោះវិធានការ E។ ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃវិធានការនេះ សូមទូរស័ព្ទទៅកាន់ការិយាល័យស្មៀនក្រុង តាមលេខ 562-570-6101 ហើយច្បាប់ចម្លងនេះ នឹងត្រូវបានផ្ញើទៅអោយអ្នកដោយឥតគិតថ្លៃ។**

CHARLES PARKIN
មេធាវីក្រុងឡុងប៊ិច